សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Royal University of Law and Economics

សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចាត់ចែងរក្សាការពារចំពោះការរើបម្រាស់ជាបណ្តោះអាសន្ន

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

រៀបរៀងឡើងដោយ
និស្សិតឈ្មោះ **ឌឹម ថារី**

សាស្ត្រាចារ្យណែនាំ
លោកស្រីមេធាវី **ខួន មករា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឌីម ថារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៦ ឆ្នាំសិក្សា ២០១២-២០១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- លោកឪពុក អ្នកម្តាយ ដ៏មានគុណចំពោះកូន ដែលបានចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ ទូន្មាន ប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ទាំងកំលាំងកាយ និងកំលាំងចិត្ត តាំងពីចាប់កំណើតរហូតដល់កូនពេញវ័យ ដោយមិនគិតពីការនឿយហត់ លំបាកយ៉ាងណានោះទេ ដើម្បីឱ្យកូនតស៊ូសិក្សារៀនសូត្របញ្ចប់ការសិក្សាដោយជោគជ័យ និង មានអាគតភ្លឺស្វាង។

- លោកឯកឧត្តមសាកលវិទ្យាធិការ និង លោកឯកឧត្តមសាកលវិទ្យធិការរង ព្រមទាំងលោក និងលោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់រូបខ្ញុំបាទ យ៉ាងយកចិត្តទុកដាក់អស់ពីកំលាំងកាយ និងកំលាំងចិត្ត នូវគ្រប់មុខវិជ្ជាដ៏មានតម្លៃ ដែលជាប្រទីបបំភ្លឺផ្លូវនៅពេលអនាគត។

-លោកស្រីសាស្ត្រាចារ្យ **ខួន មករា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ សម្រាប់ការបង្ហាត់បង្រៀន និងបានដឹកនាំរូបខ្ញុំបាទក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ រហូតដល់ទទួលបានជោគជ័យ និងបានផ្តល់មតិយោបល់ល្អៗនានា ថែមទាំងណែនាំរូបខ្ញុំបាទអស់ពីកំលាំងកាយ កំលាំងចិត្ត ព្រមទាំងបានប្រគល់ឯកសារជាច្រើនដ៏ល្អមានតម្លៃក្នុងការស្រាវជ្រាវអំពីប្រធានបទសារណានេះ។

-អរគុណដល់ លោកយាយ លោកតា លោកអ៊ំ លោកពូ បងប្អូនប្រុសស្រី ព្រមទាំងមិត្តប្រុសស្រីដែលបានផ្តល់កំលាំងចិត្ត និងជួយផ្តល់មតិយោបល់ល្អៗដល់រូបខ្ញុំក្នុងការសិក្សាពេលកន្លងមក។

-ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរឱ្យពួកអស់លោកទាំងអស់ខាងលើ ឱ្យជួបពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពេលដែលរូបខ្ញុំបាទសិក្សាអស់រយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្ររួចមក ធ្វើឱ្យរូបខ្ញុំបាទបានទទួលចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនពីថ្នាក់ដឹកនាំ និងសាស្ត្រាចារ្យ។ មូលហេតុដែលជម្រុញឱ្យខ្ញុំបាទសម្រេចចិត្តជ្រើសរើសយកប្រធានបទ ″ នីតិវិធីនៃការចាត់ចែងរក្សាការពារចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ″ ខាងលើនេះព្រោះតែនៅក្នុងសង្គមយើងជាក់ស្ដែងមានការអនុវត្តច្រើនដែលទាក់ទងទៅនឹងការរឹបអូសជាបណ្ដោះអាសន្ន ម្យ៉ាងទៀតវាមានការលំបាកយ៉ាងខ្លាំងនៅក្នុងស្វែងយល់អំពីនីតិវិធីនេះ ដែលតម្រូវឱ្យមានការសិក្សាស្វែងយល់ និងស្រាវជ្រាវបន្ថែមទៀតដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន។

ជាចុងបញ្ចប់ខ្ញុំសង្ឃឹមយ៉ាងម៉ុតមាំ ថាសារណានេះអាចចូលរួមចំណែកនៅក្នុងការពង្រីកចំនេះដឹងបន្ថែមដល់អ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងនៅក្នុងការសិក្សាស្វែងយល់បន្ថែម។ ទោះបីជាយ៉ាងណាក៏ដោយសារណានេះ ប្រាកដជាមានកំហុសឆ្គង ឬ មានចំណុចខ្វះខាតត្រង់កន្លែងណាមួយជាក់ជាមិនខានក្នុងការតាក់តែងសារណានេះឡើង ដែលតម្រូវឱ្យមានការរិះគន់ចាំបាច់នៅក្នុងន័យស្ថាបនា ពីសំណាក់សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ ដើម្បីធ្វើការកែលំអនូវចំណុចខ្វះខាតទាំងអស់នោះ។

ខ្ញុំបាទសូមអភ័យទោសនូវកំហុសឆ្គងពាក្យពេជន៍ អក្ខរាវិរុទ្ធមួយចំនួន ឬ រាល់ចំណុចខ្វះខាតទាំងឡាយណាដែលកើតមានឡើងដោយចេតនាក្តី និងអចេតនាក្តី។ ខ្ញុំបាទរង់ចាំទទួលនូវការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យសារណានេះកាន់តែល្អប្រសើរឡើង។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** ---------- ១

**ជំពូកទី១ សញ្ញាណទូទៅនៃការរឹបអូសជាបណ្ដោះអាសន្ន**

១. ខ្លឹមសារនៃការរឹបអូសជាបណ្ដោះអាសន្ន ---------- ៣

២. ចរិកលក្ខណៈនៃចាត់ចែងរក្សាការពារ ---------- ៤

២.១.លក្ខណៈបណ្ដោះអាសន្ន ---------- ៤

២.២.លក្ខណៈបន្ទាន់បង្ខំ ---------- ៤

២.៣.លក្ខណៈបន្ទាន់បន្សំ ---------- ៤

២.៤.លក្ខណៈសម្ងាត់ ---------- ៥

**ជំពូកទី២ នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

១.ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ---------- ៦

២.សមត្ថកិច្ចយុត្តាធិកា ---------- ៦

២.១.តុលាការមានសមត្ថកិច្ចលើអង្គសេចក្ដី ---------- ៧

២.២.សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ---------- ៧

៣.ពាក្យសុំដីកាសម្រេចរក្សាការពារចំពោះការរឹបអូសជាបណ្ដោះអាសន្ន ---------- ៧

៣.១.ចំណុចដែលត្រូវសរសេរ ---------- ៧

៣.២.សេចក្ដីបញ្ជាក់ដំបូង ---------- ៨

៤.សោហុយនៃការរក្សាការពារ ---------- ៨

៤.១.ពន្ធដាក់ពាក្យសុំ ---------- ៨

៤.២.ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ ---------- ៩

៤.៣.បន្ទុកនៃប្រាក់ប្រដាប់ក្ដី ---------- ៩

៥.ប្រាតិភោគនៃការរឹបអូសជាបណ្ដោះអាសន្ន ---------- ៩

៥.១.គោលបំណងនៃការដាក់ប្រាតិភោគ ---------- ១០

៥.២.វិធីដាក់ប្រាតិភោគ ---------- ១០

៥.៣.ចំនួននៃប្រាតិភោគ ---------- ១០

៥.៤.អំឡុងពេលដាក់ប្រាតិភោគ ---------- ១១

៦.ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន ---------- ១១

៦.១.គោលបំណងនៃការដាក់ប្រាក់រំដោះ------------------------------------------------------------------------------ ១១

៦.២.ចំនួនប្រាក់រំដោះពីរឹបអូសជាបណ្តោះអាសន្ន ------------------------------------------------------------------ ១២

**ជំពូកទី៣ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

១.ស្ថាប័នចាត់ចែង និងប្រតិបត្តិការបញ្ជូន------------------------------------------------------------------------------- ១៣

២.ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង ------------------------------------------------------------------- ១៤

៣.វិធីនៃការបញ្ជូន ---------------------------------------------------------------------------------------------------------- ១៥

៣.១.ការបញ្ជូនដោយការប្រគល់---------------------------------------------------------------------------------------- ១៥

៣.២ ការបញ្ជូនដោយជួបប្រទះ ------------------------------------------------------------------------------------------ ១៦

៣.៣.ការបញ្ជូនដោយបង្គ្រប់កិច្ច ----------------------------------------------------------------------------------------- ១៦

៣.៤.ការបញ្ជូនដោយទុកចោល-------------------------------------------------------------------------------------------- ១៦

៣.៥ ការបញ្ជូនទៅបរទេស ------------------------------------------------------------------------------------------------ ១៧

៣.៦ ការបញ្ជូនតាមការផ្សាយជាសាធារណៈ---------------------------------------------------------------------------- ១៧

**ជំពូកទី៤ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**

១ ស្ថាប័នអនុវត្តរឹបអូសជាបណ្តោះអាសន្ន---------------------------------------------------------------------------------២០

២ ពាក្យសុំឱ្យរឹបអូសជាបណ្តោះអាសន្ន ----------------------------------------------------------------------------------២១

២.១ ពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន-----------------------------------------------------------------------------២១

២.២ ឯកសារដែលត្រូវភ្ជាប់-----------------------------------------------------------------------------------------------២១

៣ ការពិនិត្យមើលពាក្យសុំ--------------------------------------------------------------------------------------------------២២

៤ ការពិនិត្យលក្ខខណ្ឌចាំបាច់នៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន---------------------------------------------២២

៥ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ------------------------------------------------------------------------------------ ២៣

៥.១ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ---------------------------------------------------------- ២៣

៥.២ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ---------------------------------------------------------២៤

៥.៣ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ ចំពោះសិទ្ធលើទ្រព្យសម្បត្តិផ្សេងទៀត ------------------------------------------------------------------------------------------------------------២៦

៥.៤ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា------------------------------------------------------------------២៦

**ជំពូកទី ៥ បណ្តឹងឧបាស្រ័យចំពោះការរឹបអូសជាបណ្តោះអាសន្ន**

១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន---------------------------------------------------------------២៨

១.១ នីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ា -------------------------------------------------------------------២៨

២ ការតវ៉ាចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ------------------------------------------------២៩
៣ ការសុំឱ្យលុបចោល និងការផ្អាកលើដីកាសម្រេចរក្សាការពារ ---------------------------------- ៣០
៤ បណ្តឹងជំទាស់------------------------------------------------------------------------------------ ៣០
៥ នីតិវិធី និងអំឡុងពេលបណ្តឹងជំទាស់------------------------------------------------------------ ៣១
៦ ការសុំឱ្យជំនុំជម្រះសារជាថ្មី------------------------------------------------------------------- ៣១
សេចក្តីសន្និដ្ឋាន---------------------------------------------------------------------------------- ៣២
អនុសាសន៍ ------------------------------------------------------------------------------------- ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងបោះជំហានទៅជានីតិរដ្ឋយ៉ាងពិតប្រាកដ បើធៀបទៅប្រទេសកម្ពុជានាពេលប៉ុន្មានឆ្នាំមុននេះ ព្រោះថាប្រទេសកម្ពុជាបច្ចុប្បន្ននេះកំពុងអនុម័តច្បាប់ថ្មីៗជាច្រើន ដែលជាតម្រូវការយ៉ាងចាំបាច់របស់ប្រជាពលរដ្ឋ ក៏ដូចជាសង្គមជាតិទាំងមូល។ ទន្ទឹមនឹងគ្នានេះផងដែរ ការអនុម័តច្បាប់ថ្មីៗ រាជរដ្ឋាភិបាលដែលជាស្ថាប័នអនុវត្តច្បាប់ក៏បានខិតខំប្រឹងប្រែង ពង្រឹងនូវសមត្ថភាពរបស់ខ្លួន និងស្ថាប័នក្រោមឱវាទនានា ដើម្បីអនុវត្តច្បាប់ថ្មីនេះ ឱ្យទទួលបាននូវប្រសិទ្ធភាព និង តម្លាភាព ក្នុងការធានាឱ្យបានសន្តិភាព សុវត្ថិភាព សន្តិសុខ របៀបរៀបរយ និងសណ្តាប់ធ្នាប់សាធារណៈ ជូនសង្គមក៏ដូចជាប្រទេសជាតិទាំងមូលផងដែរ។

ដោយសារមានភាពរីកចំរើនគ្មានដែនកំណត់របស់ប្រទេសកម្ពុជា ដែលជាប្រទេសប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយបានគោរពទៅលើសិទ្ធិ និងសេរីភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្ម និងសិទ្ធិក្នុងការធ្វើសកម្មភាពទាំងឡាយរបស់ប្រជាពលរដ្ឋដើម្បីធានាជីវភាពរស់នៅដោយសេចក្តីថ្លៃថ្នូរ និង ភាពសុខសាន្តនៅក្នុងសង្គម ព្រមទាំងទទួលស្គាល់នូវរបបកម្មសិទ្ធិឯកជនផងដែរ។ ដើម្បីឆ្លើយតបទៅនឹងភាពរីកចម្រើនគ្មានដែនកំណត់ជាមួយនឹងការប្រែប្រួលស្ថានភាពសង្គម រដ្ឋបានបង្កើតឲ្យមានរបបគតិយុត្តទំនើបឱ្យស្របទៅតាមស្ថានភាពជាក់ស្តែងរបស់សង្គមក្នុងគោលបំណង ដើម្បីគ្រប់គ្រប់ទៅលើគ្រប់សកម្មភាពនានារបស់ប្រជាពលរដ្ឋប្រកបទៅដោយប្រសិទ្ធភាពក្នុងការគ្រប់គ្រងសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈក្នុងការការពារការខ្វែងគំនិតគ្នាខាងផលប្រយោជន៍ ដែលជាហេតុបង្កើតជាជម្លោះ។ នៅក្នុងនោះផងដែរ ប្រទេសកម្ពុជាយើងបានបង្កើតប្រព័ន្ធគតិយុត្ត និងបទដ្ឋានគតិយុត្តជាច្រើនដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតផងដែរ។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើងដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦ មានគន្ថីចំនួនប្រាំបួន។ នៅក្នុងគន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារដែលក្នុងនោះមានចែងអំពីការរឹបអូសជាបណ្តោះអាសន្នផងដែរចាប់ពីមាត្រា៥៣០ ដល់មាត្រា ៥៧១។

ដូចនេះ តើការអនុវត្តរឹបអូសជាបណ្តោះអាសន្នអាចអនុវត្តទៅបានត្រូវមានលក្ខខណ្ឌអ្វីខ្លះ? តើម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តអាចធ្វើសកម្មភាពស្របច្បាប់បានអ្វីខ្លះចំពោះទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននោះ? តើអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធត្រូវអនុវត្តសកម្មភាពរបស់ខ្លួនដូចម្តេចខ្លះ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ននោះ?

ដើម្បីធ្វើការបកស្រាយ នឹងឆ្លើយនូវសំណួរខាងលើទាំងនេះ យើងសូមធ្វើការបកស្រាយក្នុងប្រធានបទសារណានេះ ដោយធ្វើការបែងចែកជាប្រាំជំពូកដូចខាងក្រោមនេះ ៖

ជំពូកទី ១៖ សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្ន

ជំពូកទី ២៖ នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ជំពូកទី ៣៖ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ជំពូកទី ៤៖ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

ជំពូកទី ៥៖ បណ្តឹងឧបាស្រ័យចំពោះការរឹបអូសជាបណ្តោះអាសន្ន

# ជំពូកទី ១ សញ្ញាណទូទៅនៃការរឹបអូសជាបណ្ដោះអាសន្ន

ការរឹបអូសជាបណ្ដោះអាសន្ន គឺជានីតិវិធីមួយដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសឱ្យប្រើថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦។ ការរឹបអូស ជាបណ្ដោះអាសន្ន ស្ថិតនៅក្នុងគន្ថីទី ៧ ការចាត់ចែងរក្សាការពារ។

ការចាត់ចែងរក្សាការពារចែកចេញជាបីប្រភេទដែលមានខ្លឹមសារដូចខាងក្រោម[1]៖

ក. ការរឹបអូសជាបណ្ដោះអាសន្ន គឺជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិ របស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោល បំណងឱ្យសងជាប្រាក់។

ខ. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាការចាត់ចែងដែល រក្សាទុកស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទក្នុងករណីមានការបារម្ភថា ម្ចាស់បំណុលនឹង មិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួល ស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។

គ. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គឺជាការចាត់ចែង ដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់ពេលដែលសាលក្រម ឬ សាលដីកានោះចូល ជាស្ថាពរ នៅក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដែលនឹងអាចកើតមានឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។

ដូចនេះ ប្រធានបទនៃសារណានេះ គឺផ្ដោតសំខាន់ទៅលើការរឹបអូសជាបណ្ដោះអាសន្ន ហើយមុននឹងឈានទៅដល់ការសិក្សា និងការបកស្រាយឱ្យស៊ីជម្រៅទៅលើប្រធានបទនេះចាំបាច់ ត្រូវស្គាល់សញ្ញាណទូទៅនៃការរឹបអូសជាបណ្ដោះអាសន្នជាមុនសិន។

## ១. ខ្លឹមសារនៃការរឹបអូសជាបណ្ដោះអាសន្ន

ការរឹបអូសជាបណ្ដោះអាសន្ន គឺវិធានការមួយដើម្បីការពារជាបណ្ដោះអាសន្ននូវសិទ្ធិរបស់ ម្ចាស់បំណុល ។ ការរឹបអូសជាបណ្ដោះអាសន្ន គឺជាប្រភេទនីតិវិធីមួយដែលតុលាការមានគោល បំណងធ្វើការធ្វើការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល មានគោលបំណងឱ្យសងជាប្រាក់តែ ប៉ុណ្ណោះ។ ប្រសិនបើ តុលាការបានធ្វើការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដោយគ្មានគោល បំណងឱ្យសងជាប្រាក់ នោះមិនមែនជានីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នឡើយ។

[1] មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ២ ចរិតលក្ខណៈនៃការរក្សាការពារ

ចរិតលក្ខណៈនៃរក្សាការពារត្រូវបានបែងចែកជាបួនផ្នែកសំខាន់ៗ លក្ខណៈបណ្តោះអាសន្ន លក្ខណៈបន្ទាប់បន្សំ លក្ខណៈបន្ទាន់បង្ខំ និងលក្ខណៈសម្ងាត់[2]។

### ២.១ លក្ខណៈបណ្តោះអាសន្ន

ដីកាសម្រេចរក្សាការពារ គឺជានីតិវិធីមួយដែលធ្វើឡើងដោយលក្ខណៈជាបណ្តោះអាសន្ន មានន័យថាដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលលើសេចក្តីសម្រេចសាលក្រមក្នុងបណ្តឹងអង្គសេចក្តី ឬ ធ្វើឱ្យសេចក្តីសម្រេចប្រែប្រួលនោះទេ។ ទោះបីជា ដីកាសម្រេចរក្សាការពារបានចេញដោយតុលាការក៏ដោយ ក៏សិទ្ធិលើបំណុល ឬ សិទ្ធិទាមទារផ្សេងៗទៀតរបស់បណ្តឹងអង្គសេចក្តីមិនត្រូវបានបញ្ជាក់ថា មានអត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងគតិយុត្តឡើយ។

### ២.២ លក្ខណៈបន្ទាន់បង្ខំ

នីតិវិធីនៃការចេញដីកាសម្រេចរក្សាការពា គឺជាការប្រញាប់ខ្លាំងណាស់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬធ្វើការការពារការខូចខាត់ដែលនឹងអាចកើតមានឡើងឆាប់ៗនៅពេលខាងមុខជាក់ជាមិនខាន។ ដូចនេះ ហើយបានជាគេសង្កេតឃើញថា នៅក្នុងនីតិវិធីនៃការរក្សាការពារ ថៅក្រមមិនសូវបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេ ដោយសារការធ្វើនីតិវិធីទាំងអស់នោះអាចខូចខាតផលប្រយោជន៍របស់ម្ចាស់បំណុលដោយការប្រើប្រាស់ពេលវេលាច្រើន។ តាមធម្មតាថៅក្រម គ្រាន់តែធ្វើការសាកសួរម្ចាស់បំណុល និងធ្វើការពិនិត្យភស្តុជាឯកសារព្រមទាំងឱ្យភាគីធ្វើសេចក្តីបញ្ជាក់ដំបូងតែប៉ុននោះ។ ចំពោះដីកាសម្រេចរក្សាការពារដែលបានចេញរួចហើយ ត្រូវធ្វើការបញ្ជូនទៅម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្ត ដើម្បីឱ្យម្ចាស់បំណុលធ្វើការអនុវត្តនៅក្នុងអំឡុងពេល២ (ពីរ) សប្តាហ៍គិតចាប់ពីពេលដែលទទួលការបញ្ជូនដីកាសម្រេចនេះ។ ប្រសិនបើម្ចាស់បំណុលដែលទទួលបានការបញ្ជូនដីកានេះក្នុងរយៈពេល២ (ពីរ) សប្តាហ៍នេះហើយមិនបានអនុវត្តទេ នោះដីកាសម្រេចនឹងអស់អនុភាពអនុវត្តហើយ[3]។

### ២.៣ លក្ខណៈបន្ទាប់បន្សំ

នីតិវិធីនៃការចាត់ចែងរក្សាការពារ គឺជានីតិវិធីបន្ទាប់បន្សំមួយប្រភេទដើម្បីធ្វើបណ្តឹងអង្គសេចក្តីមួយចំនួន។ចំពោះដីកាសម្រេចរក្សាការពារ ជានីតិវិធីមួយដែលធ្វើឡើងបណ្តោះអាសន្ន វាពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គសេចក្តីទេ ហើយវាបានកំណត់ដោយសមត្ថកិច្ចផ្តាច់មុខ នៅពេល

[2] ឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី៤ កេត សុជាតិ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
[3] មាត្រា ៥៦២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ដែលភាគីបានធ្វើការដាក់បណ្តឹងអង្គសេចក្តីទៅតុលាការដែលមានសមត្ថកិច្ច នោះការសុំពាក្យរក្សាការពារទៅតុលាការ ដែលមានសមត្ថកិច្ចលើអង្គសេចក្តីនោះដែរ។ រឿងក្តីនៃការរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ ឬ វត្ថុដែលជាកម្មវត្ថុស្ថិតនៅ[4]។ តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី១ (មួយ) ប៉ុន្តែបើអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី គឺ ជាតុលាការជំនុំជម្រះបណ្តឹងឧទ្ធរណ៍[5]។

## ២.៤ លក្ខណៈសម្ងាត់

ម្ចាស់បំណុល ឬ អ្នកដែលបានដាក់ពាក្យប្តឹងសុំការរក្សាការពារតែងតែមានការបារម្ភថា នៅពេលដែលតុលាការកំណត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរួចហើយ ខ្លួនមិនអាចអនុវត្តកិច្ចការទាំងនោះបាន ហើយម្ចាស់បំណុលតែងតែស្នើសុំមកតុលាការឱ្យធ្វើការចាត់ចែងរក្សាការពារ ។ ប៉ុន្តែពេលខ្លះតុលាការបានតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ដើម្បីកុំឱ្យប្រើសិទ្ធិនេះហួសហេតុពេកចំណែកកូនបំណុលវិញ កាលបើដឹងថាខ្លួនចាញ់ក្តីវិញ ពេលនោះខ្លួនក៏បានធ្វើការចាត់ចែងទ្រព្យសម្បត្តិនោះទៅឱ្យអ្នកដទៃទៀតក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។ ភាពសម្ងាត់នេះគឺដើម្បីរក្សាការពារផលប្រយោជន៍ឱ្យអ្នកដែលបានដាក់ពាក្យសុំរក្សាការពារ ដែលនីតិវិធីនេះធ្វើឱ្យបាត់បង់ សិទ្ធិទាមទារឱ្យសាកសួរគោលការណ៍ចំពោះមុខ ប៉ុន្តែដោយសារលក្ខណៈសម្ងាត់នេះហើយ ម្ចាស់បំណុលដែលជាអ្នកស្នើសុំដីកាសម្រេចរក្សាការពារនេះ អាចអនុវត្តការរក្សាការពារនេះបាននៅពេលដែលម្ចាស់បំណុលទទួលការបញ្ជូនពីតុលាការត្រឹមតែរយៈពេល ២ (ពីរ) សប្តាហ៍គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលការបញ្ជូនដីកាសម្រេចនេះពីតុលាការ ទោះបីជាកូនបំណុលមិនបានទទួលការបញ្ជូនដីកាសម្រេចនេះក៏ដោយ[6]។

[4] មាត្រា ៥៤០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[5] មាត្រា ៥៤០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[6] មាត្រា ៥៦២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# ជំពូកទី ២ នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

មុននឹងចេញដីការក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ន តុលាការចាំបាច់ណាស់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវសមត្ថកិច្ចទៅតាមប្រភេទនៃការចាត់ចែងរក្សាការពារ ដើម្បីជៀសវាងការអនុវត្តទៅខុសសមត្ថកិច្ច បណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិរបស់ភាគីដោយសារការអនុវត្តខុសនឹងដែនសមត្ថកិច្ចនេះ។

## ១ ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ

ដីកាសម្រេចរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ន គឺអាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើការអនុវត្តទៅបាន ឬ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំមានការលំបាកយ៉ាងខ្លាំង[7]។ ដីកាសម្រេចនេះវាត្រូវផ្អែកទៅលើភាពរួមគ្នារវាងសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារផងដែរ ដោយមិនផ្អែកទៅលើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងបានត្រូវរក្សាការពារតែមួយមុខនោះទេ ។ នៅក្នុងស្ថានភាពដែលម្ចាស់បំណុលមានការបារម្ភថា អចលនវត្ថុ ឬ ទ្រព្យសម្បត្តិផ្សេងៗទៀតរបស់កូនបំណុល មានការចាត់ចែង ឬ មានការផ្ទេរជាដើម ឬ ក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬ បានប្តូរលំនៅឋានជាច្រើនលើក ដែលនេះជាឧបសគ្គមួយក្នុងការអនុវត្តដោយបង្ខំ។ ភាពចាំបាច់នេះ ម្ចាស់បំណុលត្រូវតែសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ ជាពិសេសព័ត៌មានដែលទាក់ទងទៅនឹងស្ថានភាពហានិភ័យលើទ្រព្យសម្បត្តិរបស់កូនបំណុល។

## ២ សមត្ថកិច្ចយុត្តាធិការ

សមត្ថកិច្ចរបស់តុលាការ គឺវាមានសារៈសំខាន់ណាស់សម្រាប់ការវិនិច្ឆ័យចំពោះការចេញដីកាសម្រេចរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ននេះ។ នៅពេលម្ចាស់បំណុលបានដាក់ពាក្យសុំទៅតុលាការណាមួយ តុលាការនោះត្រូវពិនិត្យមើលអត្ថិភាព ឬ និត្ថភាព និងទំនាក់ទំនងគតិយុត្តនៃសមត្ថកិច្ចរបស់ខ្លួនព្រមទាំងភាពត្រឹមត្រូវនៃពាក្យសុំផង។ កាលបើ តុលាការយល់ឃើញថា ខ្លួនមិនមានសមត្ថកិច្ចលើរឿងក្តីនៃការចាត់ចែងរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ននោះទេ តុលាការនោះត្រូវផ្ទេររឿងក្តីនោះ ទៅតុលាការដែលមានសមត្ថកិច្ចតាមរយៈពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

[7] មាត្រា ៥៤០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

### ២.១ តុលាការមានសមត្ថកិច្ចលើអង្គសេចក្តី

អង្គសេចក្តី គឺជារឿងក្តីនៃបណ្តឹងដែលពាក្យបណ្តឹងត្រូវបានដាក់ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ។ មុននឹងពេលដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការមានសមត្ថកិច្ច គឺជាតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃបណ្តឹងដែលនឹងធ្វើនាពេលអនាគត។ ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទី១ (មួយ) ប៉ុន្តែបើអង្គសេចក្តីត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍[8]។ ប្រសិនបើអង្គសេចក្តីកំពុងត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងសារទុកនៅតុលាការកំពូល នោះត្រូវត្រលប់ទៅរកគោលការណ៍ដើមវិញ គឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តីគឺជាតុលាការនៃការជំនុំជម្រះលើកទី ១ (មួយ) ដដែល។

### ២.២ សាលាដំបូងមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ

ក្រៅពីសមត្ថកិច្ចលើអង្គសេចក្តី ច្បាប់ក៏បានអនុញ្ញាតិឱ្យសាលាដំបូងណាដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅផងដែរ។ នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននោះ គឺជាវត្ថុក្រៅពីចលនវត្ថុ នោះអ្នកដាក់ពាក្យសុំត្រូវបញ្ជាក់ពីវត្ថុដែលជាកម្មវត្ថុនោះឱ្យបានច្បាស់លាស់។

## ៣ ពាក្យសុំដីការសម្រេចរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ន

ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ[9]។ ការតម្រូវឱ្យដាក់ពាក្យសុំ ដែលជាមូលដ្ឋានក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្ន ធ្វើជាលាយលក្ខណ៍អក្សរដើម្បីធានានូវភាពច្បាស់លាស់។

### ៣.១ ចំណុចដែលត្រូវសរសេរ

ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារដែលធ្វើចំពោះការរឹបអូសជាបណ្តោះអាសន្ន អ្នកដែលដាក់ពាក្យសុំត្រូវសរសេរបញ្ជាក់ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់បំផុតផងដែរនូវចំណុចដូចជា ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនិងឈ្មោះរបស់អ្នកតំណាងដែលច្បាប់បានកំណត់, ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ, សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានធ្វើការរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ។

[8] មាត្រា ៥៤០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[9] មាត្រា ៥៣៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

**ក. ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់** ៖ ត្រង់ចំណុចនេះ គឺវាទាក់ទងទៅនឹងអត្តសញ្ញាណរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ ហើយត្រូវសរសេរឱ្យបានច្បាស់លាស់ថាតើអ្នកណាជាអ្នកប្ដឹង? ឈ្មោះអ្វី? តើអ្នកនោះមានអាសយដ្ឋាននៅទីណា? តើមានអ្នកតំណាងដែលច្បាប់បានកំណត់អត់? បើមានអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះនិងអាស័យដ្ឋាន ព្រមទាំងលេខទូរស័ព្ទផងដែរ។

**ខ. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ** ៖ នៅត្រង់ចំណុចនេះ អ្នកដាក់ពាក្យសុំ ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃដីការក្សាការពារ ថាតើខ្លួនបំណងចង់រក្សាការពារទៅលើ ចលនវត្ថុ ឬអចលនវត្ថុ ឬសិទ្ធិលើបំណុល ឬនាវាជាដើម។

**គ. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ** ៖ នៅក្នុងចំណុចនេះ អ្នកដាក់ពាក្យសុំត្រូវសរសេររៀបរាប់អំពីមូលហេតុដែលជាអង្គហេតុចាំបាច់នៃការទាមទារ និងអង្គហេតុផ្សេងៗទៀតនៃការទាមទារប្រសិនបើមាន ព្រោះដើម្បីឱ្យតុលាការថ្លឹងថ្លែងពិចារណាទៅលើភាពចាំបាច់នៃការការពារចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់អ្នកដាក់ពាក្យសុំ។

**ឃ. ភាពចាំបាច់នៃការរក្សាការពារ** ៖ នៅក្នុងចំណុចនេះ អ្នកដាក់ពាក្យសុំត្រូវលើកយកភាពចាំបាច់ទាំងឡាយដែលត្រូវរក្សាការពារ ដើម្បីឱ្យចៅក្រមពិនិត្យនិងពិចារណា។

### ៣.២ សេចក្ដីបញ្ជាក់ដំបូង

នៅក្នុងពាក្យសុំដីការក្សាការពារចំពោះការរឹបអូសជាបណ្ដោះអាសន្ននេះ ចំណុចដែលត្រូវសរសេរដូចដែលបានរៀបខាងលើនេះ អ្នកដែលដាក់ពាក្យសុំត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងនូវចំណុចសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារនេះ[10]។ សេចក្ដីបញ្ជាក់ដំបូង គឺត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។

## ៤ សោហ៊ុយនៃការរក្សាការពារ

ដើម្បីឱ្យការចាត់ចែងរក្សាការពារដំណើរការទៅបាន អ្នកដាក់ពាក្យសុំត្រូវបង់សោហ៊ុយជាមុនដើម្បីចំណាយលើការប្រើប្រាស់ក្នុងការអនុវត្តរក្សាការពារ។

### ៤.១ ពន្ធដាក់ពាក្យសុំ

នៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារ អ្នកដែលដាក់សុំឱ្យចេញដីកាសម្រេចរក្សាការពារត្រូវបង់ពន្ធចំនួន ៥០០០ (ប្រាំពាន់) រៀលទៅតុលាការ ប្រសិនបើអ្នកដែលដាក់ពាក្យសុំឱ្យចេញដីកា

[10] មាត្រា ៥៤១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

សម្រេចរក្សាការពារមិនបានបង់ពន្ធទេ តុលាការបង្គាប់ឱ្យអ្នកដែលដាក់ពាក្យសុំបង់ពន្ធក្នុងអំឡុងពេលសមរម្យ[11]។ ក្នុងករណីអ្នកដែលដាក់ពាក្យសុំនៅតែមិនព្រមបង់ពន្ធ ដែលកំណត់ពេលដោយតុលាការទេ តុលាការអាចលើកពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនេះបានដោយដីកាសម្រេច។

ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង។

### ៤.២ ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ គឺជាប្រភេទប្រាក់ដែលតុលាការតម្រូវឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ជាមុនដែលកំណត់ដោយតុលាការ សម្រាប់ធ្វើសកម្មភាពតាមនីតិវិធីនៃការចាត់ចែងរក្សាការពារ ដូចជាចំនួនទឹកប្រាក់សម្រាប់ធ្វើការបញ្ជូនឯកសារជាដើម។

### ៤.៣ បន្ទុកនៃប្រាក់ប្រដាប់ក្ដី

ពេលដែលតុលាការធ្វើការសម្រេចសេចក្ដីនៅក្នុងរឿងរក្សាការពារ នៅក្នុងសេចក្ដីសម្រេចនោះត្រូវកំណត់អ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

នៅពេលដែលមានចេញដីកាសម្រេចទទួលស្គាល់ពាក្យសុំ ប្រាក់ប្រដាប់ក្ដីត្រូវបានធ្វើឡើងក្នុងវិធី ២ (ពីរ) យ៉ាង៖

**វិធីទី១** ៖ គឺថាដីកាសម្រេចមិនកំណត់បន្ទុកនៃប្រាក់ប្រដាប់ក្ដី ដីកាសម្រេចសេចក្ដីនោះត្រូវដាក់ទៅតុលាការដែលចេញសេចក្ដីសម្រេចនោះ។ ដូចនេះហើយដីកាសម្រេចនេះមិនឆ្លើយតបទៅនឹងដីកាសម្រេចសេចក្ដីដែលបញ្ចប់រឿងក្ដីនៅតុលាការឡើយ។

**វិធីទី២** ៖ គឺដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចត្រូវកំណត់អំពីចំនួនប្រាក់ប្រដាប់ក្ដី។ ដោយហេតុថាជានិច្ចជាកាល បណ្ដឹងជំទាស់តែងតែមិនត្រូវបានគេធ្វើឡើងចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នឡើយ ។ នៅក្នុងករណីបែបនេះបន្ទុកនៃប្រាក់ប្រដាប់ក្ដីមិនត្រូវបានសម្រេចឡើយ។ ដើម្បីជៀសវាងស្ថានភាពបែបនេះ គេបកស្រាយថា ដីកាសម្រេចដែលទទួលស្គាល់តាមពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវកំណត់បន្ទុកប្រាក់ប្រដាប់ក្ដី។

## ៥ ប្រាតិភោគនៃការរឹបអូសជាបណ្ដោះអាសន្ន

ដីកាសម្រេចរក្សាការពារ អាចធ្វើឡើងដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន[12] តាមធម្មតានៅក្នុងការអនុវត្តជាក់ស្ដែង គឺតម្រូវឱ្យអ្នកដែលដាក់ពាក្យសុំត្រូវដាក់ប្រាតិភោគច្រើនជាងការដែលមិនឱ្យដាក់ប្រាតិភោគ។

---

[11] មាត្រា ៥៣៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[12] មាត្រា ៥៤២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ៥.១ គោលបំណងនៃការដាក់ប្រាតិភោគ

ចំណុចពិសេសនៃការរឹបអូសជាបណ្តោះអាសន្ន គឺតុលាការអាចចេញដីកាសម្រេចនេះបាន ដោយពុំចាំបាច់សួរកូនបំណុលឡើយ ដោយគ្រាន់តែឆ្លងកាត់ការធ្វើសេចក្តីបញ្ជាក់ដំបូងគឺជាការគ្រប់គ្រាន់ ។ ក្នុងករណីខ្លះការចេញដីកាសម្រេច គឺអាចបណ្តាលឱ្យមានការប៉ះពាល់យ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់កូនបំណុល ដែលអាចឱ្យកូនបំណុលមានការខូចខាត់ច្រើនដោយសារការរឹបអូសនេះ។ ដើម្បីជាការឆ្លើយតបទៅនឹងការខូចខាតរបស់កូនបំណុល ដែលអាចកើតឡើងជាយថាហេតុនោះ ទើបតុលាការបានតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ ការដាក់ប្រាតិភោគនេះដើម្បីសងការខូចខាត និងជម្ងឺចិត្ត។

## ៥.២ វិធីដាក់ប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគធានាដល់ការអនុវត្តដោយរឹបអូសជាបណ្តោះអាសន្ន គឺភាគីធ្វើតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន(ចលនវត្ថុ អចលនវត្ថុ និង វត្ថុដទៃទៀត អាចលក់ដូរបាន) ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តរក្សាការពារ[13]។

## ៥.៣ ចំនួននៃប្រាតិភោគ

នៅពេលដែលតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការត្រូវពិចារណាឱ្យបានល្អិតល្អន់ពីផលប៉ះពាល់ ដែលនាំឱ្យមានការខូចខាតកើតឡើងជាយថាហេតុ ដោយសារការចេញដីកាសម្រេចនេះ។ ដូចនេះ តុលាការត្រូវសាកល្បងធ្វើការវាយតម្លៃ អំពីទំហំនៃការខូចខាតដែលនឹងអាចកើតមានឡើងចំពោះកូនបំណុល ដោយមានការប្រុងប្រយត្ន័បំផុត ។ ក្រោយពីតុលាការពិចារណា លើការខូចខាតនៅពេលខាងមុខ តុលាការក៏ពិចារណាទៅលើការធ្វើសេចក្តីបញ្ជាក់ដំបូង មានន័យថាបើការធ្វើសេចក្តីបញ្ជាក់ដំបូងនោះ មានលក្ខណៈរឹងមាំនោះ ចំនួននៃការដាក់ប្រាតិភោគទាប ឬ តិចទៅតាមការធ្វើសេចក្តីបញ្ជាក់ដំបូងនោះ។ ផ្ទុយទៅវិញ បើការធ្វើសេចក្តីបញ្ជាក់ដំបូងនោះ ពុំមានលក្ខណៈរឹងមាំ នោះតុលាការតម្រូវឱ្យដាក់ប្រាតិភោគ ច្រើន ឬ ខ្ពស់ ។ នៅត្រង់ចំណុចចុងក្រោយនេះតុលាការ ត្រូវកំណត់ និងធ្វើការពិចារណាឱ្យបានត្រឹមត្រូវ ព្រមទាំងល្អិតល្អន់ផងដែរទៅលើសណ្ឋាននៃវត្ថុ ដែលជាកម្មវត្ថុនៃការចេញដីកាសម្រេចនោះ ទើបមានលក្ខណៈងាយស្រួលដល់តុលាការក្នុងការកំណត់ចំនួនប្រាតិភោគ ដែលតម្រូវឱ្យម្ចាស់បំណុលធ្វើការដាក់ប្រាតិភោគនេះបានត្រឹមត្រូវ។

[13] មាត្រា ៥៣៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

### ៥.៤ អំឡុងពេលដាក់ប្រាតិភោគ

តុលាការអាចបង្គាប់ឱ្យដាក់ប្រាតិភោគ មុនពេលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលជាលក្ខខណ្ឌក្នុងការចេញដីកាសម្រេចនេះ។ ក្នុងករណីនេះ ម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ មុនពេលចេញដីកាសម្រេច បើមិនដូចនេះទេ តុលាការអាចធ្វើការបដិសេធមិនចេញដីកាសម្រេច រហូតដល់ប្រាតិភោគត្រូវបានដាក់។ ក្នុងករណីនេះ តុលាការនឹងចេញដីកាសម្រេចអំពីប្រាតិភោគ ហើយបើម្ចាស់បំណុលដាក់ប្រាតិភោគមុនចេញដីកាសម្រេចនោះ ម្ចាស់បំណុលត្រូវធ្វើសេចក្ដីថ្លែងការណ៍ ឬ របាយការណ៍អំពីការដាក់ប្រាតិភោគទៅកាន់តុលាការឱ្យបានដឹងអំពីការដាក់ប្រាតិភោគរបស់ខ្លួន។ ម្យ៉ាងវិញទៀត តុលាការក៏អាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដែលភ្ជាប់ជាមួយការបង្គាប់ឱ្យដាក់ប្រាតិភោគ។ ការដាក់ប្រាតិភោគនេះ គឺជាលក្ខខណ្ឌមួយដើម្បីអនុវត្តដីកាសម្រេច ដូចនេះហើយម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនពេលសុំការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មានន័យថាម្ចាស់បំណុលមិនអាចអនុវត្តដីកាសម្រេចនោះបានឡើយប្រសិនបើខ្លួនមិនបានដាក់ប្រាតិភោគ។

## ៦ ប្រាក់រំដោះនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។ ការផ្ញើប្រាក់រំដោះពីការអនុវត្តនេះ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តរក្សាការពារ[14]។

### ៦.១ គោលបំណងនៃការដាក់ប្រាក់រំដោះ

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺនាំឱ្យមានការចាត់ចែងដែលមានកម្រិតការចាត់ចែងទៅលើទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ប៉ុន្តែនៅពេលដែលបានផ្ញើរប្រាក់ស្មើនឹងចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ឬ ចំនួនទឹកប្រាក់នៃកម្មវត្ថុដែលបានរឹបអូសជាបណ្ដោះអាសន្ននោះរួចហើយ ភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្ននោះមិនមានអាទិភាពទេ ។ ការដាក់ប្រាក់រំដោះនេះ មានគោលបំណងដើម្បីការពារផលប្រយោជន៍របស់កូនបំណុល និងម្ចាស់បំណុល បើកូនបំណុលផ្ញើចំនួនទឹកប្រាក់ដែលបានកំណត់ដោយតុលាការ កូនបំណុលអាចរួចផុតពីរឹបអូសជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្ននេះហើយ គឺកូនបំណុលក៏

[14] មាត្រា ៥៤៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

អាចប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិនេះបានដោយសេរី ព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្ននេះ ត្រូវបានលុបចោលដោយការដាក់ប្រាក់រំដោះនេះហើយ។

### ៦.២ ចំនួនប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

ការសម្រេចអំពីចំនួននៃប្រាក់រំដោះ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមដោយពុំមានមាត្រាណាមួយដែលបានកំណត់យ៉ាងច្បាស់លាស់អំពីប្រាក់រំដោះនេះទេ គឺវាអាស្រ័យទៅលើទំហំ និងតម្លៃនៃទ្រព្យសម្បត្តិដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ននោះ។ តុលាការត្រូវពិចារណាទៅលើតម្លៃនៃទ្រព្យសម្បត្តិរបស់កូនបំណុល ដែលម្ចាស់បំណុលស្នើសុំរឹបអូសជាបណ្តោះអាសន្ន និងយកចំនួនទឹកប្រាក់នៃទ្រព្យសម្បត្តិនៃការរឹបអូសជាបណ្តោះអាសន្ន ជាចំនួននៃប្រាក់រំដោះដោយសារតែប្រាក់រំដោះ គឺជាប្រាក់មួយប្រភេទដែលសម្រាប់ដាក់ជំនួសនូវទ្រព្យសម្បត្តិដែលនឹងត្រូវបានធ្វើការរឹបអូសជាបណ្តោះអាសន្ននោះ ។

# ជំពូកទី ៣ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមនីតិវិធីដែលច្បាប់បានកំណត់ ដើម្បីធ្វើការជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្ដឹងជូនចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍[15]។ ចំណែកឯការជូនដំណឹង គឺជាវិធីមួយដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងនីតិវិធីនៃការបញ្ជូន ដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើប្រាស់គ្រប់មធ្យោបាយ ដូចជា តាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសនីយ៍ សំបុត្រ ជាដើម ដើម្បីឱ្យអ្នកដែលនឹងត្រូវទទួលការបញ្ជូននោះបានដឹង។ ដីកាសម្រេចរក្សាការពារ តុលាការត្រូវតែធ្វើការបញ្ជូនដីកាសម្រេចរក្សាការពារនេះទៅភាគី[16]។ ការបញ្ជូន ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ លើកលែងតែមានបញ្ញត្តិពិសេសក្នុងច្បាប់[17]។ ឯកសារដែលធ្វើការបញ្ជូន គឺជាឯកសារថតចម្លងលើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់[18]។

## ១ ស្ថាប័នចាត់ចែង និងប្រតិបត្តិការបញ្ជូន

មន្ត្រីដែលទទួលបន្ទុកធ្វើការបញ្ជូន គឺជាក្រឡាបញ្ជី ចំណែកឯការបញ្ជូនត្រូវបានប្រតិបត្តិដោយ បុគ្គលិកប្រៃសនីយ៍ ឬ អាជ្ញាសាលា ឬ ក្រឡាបញ្ជី[19]។

មុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន (ក្រឡាបញ្ជី) ដូចជា[20]៖

- ធ្វើ ឬ ផ្តល់សេចក្តីបញ្ជាក់នូវឯកសារ សម្រាប់ការបញ្ជូន។

- ប្រគល់អំណាចនៃការបញ្ជូនឯកសារនោះ ទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។

-បន្ទាប់មកទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនរួចមកហើយ ក្រឡាបញ្ជីត្រូវយករបាយការណ៍នៃការបញ្ជូននោះទៅជូនចៅក្រម ដើម្បីឱ្យចៅក្រមធ្វើការពិនិត្យមើល ថាតើការបញ្ជូននេះត្រឹមត្រូវហើយ ឬ នៅ។

- ជាចុងក្រោយ មន្ត្រីរដ្ឋបាលដែលទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវរក្សាទុករបាយការណ៍នៃការបញ្ជូននេះទុកនៅក្នុងសំណុំរឿង ដោយរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ និងឱ្យបានល្អបំផុតទៅតាមកាលបរិច្ឆេទនៃលំដាប់ឯកសារទាំងអស់នោះ ដើម្បីបញ្ជាក់ថាឯកសារដែលត្រូវធ្វើការបញ្ជូននោះ គឺបានបញ្ជូនទៅដល់អ្នកដែលត្រូវទទួលការបញ្ជូនរួចហើយ។

[15] ឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី ៤ ហេង សុខណា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
[16] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[17] មាត្រា ២៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[18] មាត្រា ២៤៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[19] មាត្រា ២៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[20] ឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី ៤ ហេង សុខណា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

មុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដូចជា[21]៖

- ធ្វើការបញ្ជូនដោយជាក់លាក់ចំពោះជនដែលត្រូវទទួលការបញ្ជូន។
- ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូន[22]។
- ត្រូវដាក់របាយការណ៍អំពីការបញ្ជូននេះទៅតុលាការដើម។

របាយការណ៍បញ្ជូនដែលដែលមន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើ ត្រូវបញ្ជាក់ចំណុចដូចជា[23]៖

ក. សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។

ខ. ជនដែលត្រូវទទួលការបញ្ជូន។

គ. ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងដែលបានបញ្ជូន។

ឃ. វិធីបញ្ជូន។

ង. ចំណាត់ការក្នុងការបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ។

ច. ហត្ថលេខា ឬ ស្នាមមេដៃរបស់អ្នកទទួលឯកសារ។

ឆ. ហេតុការណ៍ដែលអ្នកទទួលការបញ្ជូនមិនព្រមទទួល ( ក្នុងករណីបញ្ជូនដោយបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល )។

ជ. ហេតុការណ៍ នៅក្នុងករណីនៃការបញ្ជូនតាមវិធីបង្គ្រប់កិច្ច និងទុកចោល។

ឈ. ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។

## ២ ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង

ទាល់តែបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀតបាន ទើបបុគ្គលនោះអាចធ្វើសកម្មភាពតាមតាមបណ្តឹងដោយខ្លួនឯងបាន[24]។

បុគ្គលដែលអសមត្ថភាពក្នុងការធ្វើបណ្តឹងមាន[25]៖

១. អនីតិជន។

២. ជននៅក្រោមអាណាព្យាបាលទូទៅ

៣. ជននៅក្រោមហិតូបត្ថម្ភ។

ជនទាំងបីប្រភេទនេះ  ត្រូវសកម្មភាពបណ្តឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់។ ប៉ុន្តែមានករណីលើកលែងដែលអាចឱ្យជនទាំងនោះអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន

[21] ឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី ៤ ហេង សុខណា នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
[22] មាត្រា ២៥៤ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[23] មាត្រា ២៥៤ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[24] មាត្រា ៣២ ក្រមរដ្ឋប្បវេណី ២០០៧
[25] មាត្រា ១៧ ក្រមរដ្ឋប្បវេណី ២០០៧

ដោយមិនចាំបាច់ឆ្លងកាត់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងករណីដូចជា៖

**ករណីទី១** ៖ អនីតិជនដែលទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន[26]គឺជាអនីតិជនដែលទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម មានសមត្ថភាពក្នុងការធ្វើបណ្តឹង មានត្រឹមតែបណ្តឹងដែលទាក់ទងនឹងជំនួញតែប៉ុណ្ណោះ។ ដូចនេះ ទោះបី អនីតិជនដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មក៏ដោយ ប្រសិនបើមិនមែនជាបណ្តឹងទាក់ទងទៅនឹងអាជីវកម្មដែលបានអនុញ្ញាតនោះទេ អនីតិជននោះនៅតែជាបុគ្គលអសមត្ថភាពដដែល។

**ករណីទី២** ៖ អនីតិជនដែលទទួលបានអត្តាធិនភាព ទោះបីភាគីលែងលះគ្នាហើយក៏ដោយក៏អានុភាពនៃអត្តាធិនភាពមិនរលត់ឡើយ[27]។

ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង ត្រូវបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។ ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាងរួមគ្នាច្រើននាក់ ការបញ្ជូននេះក៏អាចធ្វើទៅចំពោះតែជនណាម្នាក់ក៏ជាការគ្រប់គ្រាន់ហើយ។ ការបញ្ជូនទៅអ្នកជាប់ពន្ធនាគារ ត្រូវធ្វើការបញ្ជូនទៅប្រធានពន្ធនាគារ[28]។

## ៣ វិធីនៃការបញ្ជូន

នីតិវិធីនៃការបញ្ជូនមានច្រើនប្រភេទ ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីរបស់យើង ដូចនេះមន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូនត្រូវប្រតិបត្តិការបញ្ជូនដោយយកចិត្តទុកដាក់។

### ៣.១ ការបញ្ជូនដោយការប្រគល់

ជាគោលការណ៍ការបញ្ជូន គឺត្រូវប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ[29]។ ការបញ្ជូនត្រូវ បញ្ជូនទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលនឹងត្រូវទទួលការបញ្ជូន[30]។ លំនៅឋាន គឺជាកន្លែងដែលជាទីតាំងជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ[31] ចំណែកទីសំណាក់ គឺក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវចាត់ទុកជាលំនៅឋាន[32]។ ការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់ គឺអាចធ្វើការបញ្ជូនទៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់អ្នកតំណាងនោះបាន។

---

[26] មាត្រា ២០ ក្រមរដ្ឋប្បវេណី ២០០៧
[27] មាត្រា ២១ ក្រមរដ្ឋប្បវេណី ២០០៧
[28] មាត្រា ២៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[29] មាត្រា ២៤៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[30] មាត្រា ២៤៩ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[31] មាត្រា ៣៤ ក្រមរដ្ឋប្បវេណី ២០០៧
[32] មាត្រា ៣៥ ក្រមរដ្ឋប្បវេណី ២០០៧

### ៣.២ ការបញ្ជូនដោយជួបប្រទះ

ក្នុងករណីដែលពុំដឹងច្បាស់ថា ជនដែលត្រូវទទួលការបញ្ជូនមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និងទីស្នាក់ការក្នុងប្រទេសកម្ពុជាទេ មន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូនអាចប្រគល់ឯកសារដែលត្រូវបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូននោះ នៅកន្លែងដែលជួបប្រទះនោះបាន[33]។លើកលែងតែមានករណីដែលភាគីបានជូនដំណឹង ពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន នោះការបញ្ជូនត្រូវតែធ្វើនៅទីកន្លែងដែលភាគីបានជូនដំណឹង ។ បើសិនជនដែលត្រូវទទួលការបញ្ជូនមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និងទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាច្បាស់លាស់ និងមានការជូនដំណឹងពីទីកន្លែងដែលត្រូវទទួលការបញ្ជូនក៏ដោយ បើភាគីមិនប្រកែកចំពោះការបញ្ជូននៅទីកន្លែងដែលជួបប្រទះនោះទេ គឺអាចធ្វើការបញ្ជូនដោយជួបប្រទះបាន។

### ៣.៣ ការបញ្ជូនដោយបង្គ្រប់កិច្ច

ប្រសិនបើក្នុងករណីដែលមិនបានជួបជនដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូននោះទេ គឺអាចប្រគល់ឯកសារនោះទៅឱ្យអ្នកបំរើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យបាន[34]។

អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារៈ

**ទី១** ៖ អ្នកដែលយល់ដឹងច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន។

**ទី២** ៖ យល់ពីអត្ថន័យនៃឯកសារដែលខ្លួនបានទទួល។

**ទី៣** ៖ មានសមត្ថភាពអាចយកឯកសារនោះ ទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូន។

ឧទាហរណ៍ ៖ ភរិយាអាចទទួលជំនួសប្តី ដែលជាបុគ្គលដែលត្រូវទទួលការបញ្ជូនបាន ប៉ុន្តែបើសិនភរិយាជាអ្នកប្តឹងប្តី នោះការទទួលការបញ្ជូនរបស់ភរិយាជំនួសប្តីនឹងត្រូវចាត់ទុកជាមោឃៈ ព្រោះមានទំនាស់ផលប្រយោជន៍ ហើយមិនរំពឹងថាភរិយានឹងយកឯកសារដែលត្រូវបញ្ជូននោះទៅឱ្យប្តីនោះទេ។

### ៣.៤ ការបញ្ជូនដោយទុកចោល

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារ ដោយការបញ្ជូនដោយបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ឯកសារនោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន[35]។

---

[33] មាត្រា ២៥១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[34] មាត្រា ២៥២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[35] មាត្រា ២៥២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ឧទាហរណ៍ ៖ ដីកាត្រូវបញ្ជូនទៅឱ្យលោក **ក** ពេលអាជ្ញាសាលាយកឯកសារនោះទៅដល់ផ្ទះរបស់លោក **ក** តែមិនបានជួបលោក **ក** ទេដោយជួបតែកញ្ញា **ខ** ដែលជាអ្នកបំរើរបស់លោក **ក** អាជ្ញាសាលាអាចប្រគល់ដីកានោះទៅឱ្យកញ្ញា **ខ** ដើម្បីទុកឱ្យលោក **ក**។ ប្រសិនបើកញ្ញា **ខ** បានបដិសេធមិនព្រមទទួលដីកាដោយសំអាងថា ខ្លួនជាអ្នកបំរើមិនហ៊ានទទួល ការសំអាងបែបនេះ គឺមិនអាចនិយាយថាជាមូលហេតុត្រឹមត្រូវទេ អាជ្ញាសាលា អាចទុកដីកានៅទីនោះបាន គឺនៅចំពោះមុខកញ្ញា **ខ**។ នៅក្នុងករណីឧទាហរណ៍នេះ ប្រសិនបើកញ្ញា **ខ** បានបដិសេធមិនទទួលដោយសំអាងថា លោក **ក** និងក្រុមគ្រួសាររបស់គាត់មិននៅទេ ហើយពួកគាត់បានទៅបរទេសអស់ហើយទាល់តែ២ (ពីរ) ខែក្រោយទើបបានមកវិញ ហើយខ្លួនគ្មានមធ្យោបាយអាចទាក់ទងគាត់បានទេ ការសំអាងបែបនេះ គឺជាមូលហេតុត្រឹមត្រូវ នោះមិនអាចទុកដីកានៅទីកន្លែងនោះបានទេ។

### ៣.៥ ការបញ្ជូនទៅបរទេស

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន មានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់ ឬ ក៏ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការដែលអាចបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ នោះការបញ្ជូនចំពោះជននោះអាចមាន២ (ពីរ) របៀប៖

**របៀបទី១** ៖ ករណីជនដែលត្រូវទទួលការបញ្ជូនជាជនបរទេស គប្បីធ្វើការបញ្ជូនទៅឱ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។

**របៀបទី២** ៖ ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរ តែរស់នៅបរទេស គប្បីធ្វើការបញ្ជូនដោយប្រគល់ទៅឱ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន[36]។ មុននឹងធ្វើការបញ្ជូនទៅបរទេស តុលាការគួរគប្បីពិនិត្យមើលលើអនុសញ្ញា ឬ សន្ធិសញ្ញារវាងប្រទេសនោះ និងប្រទេសកម្ពុជា ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ព្រោះមានករណីខ្លះ ក្នុងបទដ្ឋានគតិយុត្តទាំងនោះមានការកំណត់ពីរបៀបនៃការបញ្ជូន។ ចំពោះការបញ្ជូនទៅជនបរទេស ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវប្រើតាមវិធីនៃការបញ្ជូនដូចគ្នានឹងការបញ្ជូនចំពោះជនជាតិខ្មែរដែរ។

### ៣.៦ ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបំពេញលក្ខខណ្ឌដូចជា[37]៖

១. ករណីដែលប្រឹងប្រែងស្រាវជ្រាវរកយ៉ាងណា ក៏មិនអាចដឹងពីទីកន្លែងដែលត្រូវបញ្ជូន។

[36] មាត្រា ២៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[37] មាត្រា ២៥៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

២. ករណីដែលយើងដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូនមិនអាចធ្វើទៅបានទោះយើងព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ។

៣. ករណីដែលមិនអាចធ្វើការបញ្ជូនទៅបរទេស។

៤. ករណីដែលតុលាការមិនអាចទទួលលិខិតបញ្ជាក់ ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែគិតចាប់ពីពេលបញ្ជូន។

ដើម្បីធ្វើការផ្សាយជាសាធារណៈបាន ទាល់តែមានពាក្យសុំរបស់ភាគីដែលស្នើសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និងបន្ទាប់ពីបានទទួលការអនុញ្ញាតដោយតុលាការ ក៏ប៉ុន្តែតុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈបាន ដោយឆន្ទានុសិទ្ធិរបស់ខ្លួនទោះបីជាគ្មានពាក្យសុំពីភាគីក៏ដោយ ចំពោះករណីដែលតុលាការយល់ឃើញថាមានការចាំបាច់[38]។ ប្រសិនបើការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបានធ្វើក្នុងករណីដែលលក្ខខណ្ឌ ដែលការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយ តែនៅមិនអាចបញ្ជូនបាន នោះក្រឡាបញ្ជីគប្បីជូនដំណឹងដោយរបៀបសមរម្យដោយតាមរយៈ តាមទូរស័ព្ទ ផ្ញើតាមប៉ុស្តិ៍ប្រៃសនីយ៍ ឬបិទតាមលំនៅឋាន ទីសំណាក់របស់អ្នកដែលត្រូវទទួលការបញ្ជូនជាដើម ដើម្បីឱ្យបានដឹងអំពីមូលហេតុដែលនាំឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈទៅភាគីដែលត្រូវទទួលការបញ្ជូននោះ។ ការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពីលើកទី ២ (ពីរ) ទៅចំពោះភាគីដដែល តុលាការត្រូវធ្វើដោយឆន្ទានុសិទ្ធិ ប៉ុន្តែការបញ្ជូនទៅបរទេស ត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ។

របៀបនៃការបញ្ជូនតាមផ្សាយជាសាធារណៈ[39]៖

**ទី១.** ក្រឡាបញ្ជីត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ឬ ទីកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ( អាចជាប៉ុស្តិ៍ សាលាឃុំ ជាដើម )និងត្រូវប្រកាសថាក្រឡាបញ្ជីជាអ្នករក្សាទុកឯកសារដែលបានធ្វើការបញ្ជូននេះ និងអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូនពេលណាក៏បាន។

**ទី២.** តុលាការអាចចុះក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។ ចំពោះការបញ្ជូនដែលត្រូវធ្វើទៅបរទេស ក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានក៏បាន។ តាមធម្មតានៅក្នុងការអនុវត្តជាក់ស្តែង តុលាការច្រើនតែធ្វើការចុះផ្សាយនៅក្នុងសារព័ត៌មាន។

[38] មាត្រា ២៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[39] មាត្រា ២៥៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ការបញ្ជូនតាមការផ្សាយជាសាធារណៈមានអានុភាព នៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាស។ ការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈចាប់ពីលើកទី២(ពីរ)ទៅ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីការបិទប្រកាស ចំណែកឯការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលត្រូវធ្វើនៅបរទេសវិញ នឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦ (ប្រាំមួយ) សប្តាហ៍បន្ទាប់ពីការបិទប្រកាស[40]។ អានុភាពនៅទីនេះ មានន័យថាការបញ្ជូនមានសុពលភាព ហើយត្រូវចាត់ទុកថា អ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននេះ។

[40] មាត្រា ២៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# ជំពូកទី ៤ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

ក្រោយពីតុលាការចេញដីកាសម្រេចរក្សាការពារហើយ កូនបំណុលត្រូវដាក់ពាក្យសុំអនុវត្តរក្សាការពារ ដើម្បីយកឯកសារចម្លងនៃលិខិតយថាភូតនេះទៅអនុវត្ត។

## ១ ស្ថាប័នអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

ជាទូទៅការអនុវត្តរក្សាការពារ គឺមានស្ថាប័នសម្រាប់អនុវត្តរក្សាការពារក្រោយពីតុលាការចេញដីការសម្រេចរក្សាការពារ ទៅតាមពាក្យសុំរបស់ម្ចាស់បំណុល។ ម្ចាស់បំណុលនៃការអនុវត្តរក្សាការពារ អាចដាក់ពាក្យសុំអនុវត្តទៅតុលាការ ឬ អាជ្ញាសាលាបាន។ ការដាក់ពាក្យសុំឱ្យធ្វើការអនុវត្តនេះ ត្រូវតែដាក់ទៅតុលាការ ឬ អាជ្ញាសាលាដែលមានសមត្ថកិច្ច។ ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តរក្សាការពារ គឺវាអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្តរក្សាការពារ ព្រោះការអនុវត្តរក្សាការពារនេះ ធ្វើឡើងចំពោះកម្មវត្ថុផ្សេងៗដាច់ដោយឡែកផ្សេងពីគ្នា។

**ក. ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ៖ ការអនុវត្តរក្សាការពារចំពោះការរឹបអូសជាបណ្ដោះអាសន្នលើអចលនវត្ថុ តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺជាតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ[41]។

**ខ. ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ** ៖ ចំពោះចលនវត្ថុមិនដូចគ្នាទៅនឹងអចលនវត្ថុទេ ស្ថាប័នដែលត្រូវធ្វើការរឹបអូសជាបណ្ដោះអាសន្ន គឺអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុជាកម្មវត្ថុនៃការរឹបអូសស្ថិតនៅ[42]។

**គ. ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត** ៖ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារនេះ គឺជាតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ[43]។

**ឃ. ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា** ៖ ស្ថាប័នមានសមត្ថកិច្ចចំពោះការអនុវត្តរឹអអូសជាបណ្ដោះអាសន្នចំពោះនាវាវិញ គឺតុលាការ ២(ពីរ) ដែលមានសមត្ថកិច្ច។ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ដែលធ្វើតាមរបៀបនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន គឺតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវ

[41] មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[42] មាត្រា ៥៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[43] មាត្រា ៥៦៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

មានសមត្ថកិច្ចជាតុលាការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ននេះ ចំណែកឯការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរយៈការដកលិខិតបញ្ជាក់សញ្ញាតិនាវា គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ ត្រូវជាតុលាការសមត្ថកិច្ច[44]។

## ២ ពាក្យសុំឱ្យរឹបអូសជាបណ្ដោះអាសន្ន

ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរមិនអាចធ្វើដោយផ្ទាល់មាត់បានទេ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នក៏ត្រូវចំណាយសោហុយផងដែរ។

### ២.១ ពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្ន អ្នកដែលដាក់ពាក្យសុំត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចដូចជា[45]៖

ក. ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណនៃលិខិតអនុវត្ត។

គ. សេចក្ដីសុំឱ្យអនុវត្ត តាមរយៈការអនុវត្តបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។

ឃ. សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។

ង. ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំធ្វើការអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្ដីសុំ និងទំហំនៃសេចក្ដីសុំនោះក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។

### ២.២ ឯកសារដែលត្រូវភ្ជាប់

កាលណាអ្នកដែលប្ដឹងសុំឱ្យធ្វើការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ននេះ បានទទួលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នពីតុលាការរួចហើយ អ្នកដែលបានដាក់ពាក្យសុំអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំរួមមាន៖

១. លិខិតចម្លងយថាភូតនៃការសម្រេចរក្សាការពារសម្រាប់ការសុំឱ្យអនុវត្ត៖ អ្នកប្ដឹងសុំនៃ

[44] មាត្រា ៥៦៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[45] មាត្រា ៣៤៩ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ដីកាសម្រេចនោះពុំចាំបាច់ស្នើសុំរូបមន្តអនុវត្តទេ ប៉ុន្តែបើការអនុវត្តនោះធ្វើឡើងចំពោះ ឬ សម្រាប់ជនដែលក្រៅពីភាគីនៅក្នុងរឿងក្តី ដែលបានកំណត់នៅក្នុងដីកាសម្រេច ត្រូវផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេច ដែលភ្ជាប់នឹងរូបមន្តអនុវត្ត[46]។

២. លិខិតបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិ ៖ កាលណាអ្នកប្តឹងសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បានផ្តល់សិទ្ធិអំណាចដល់អ្នកតំណាងដោយអាណត្តិ សិទ្ធិអំណាចនោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប៉ុន្តែបើមានបណ្តឹងអង្គសេចក្តីហើយ ហើយមានលិខិតប្រគល់សិទ្ធិអ្នកតំណាងដោយអាណត្តិ នោះអ្នកតំណាងអាណត្តិក៏អាចធ្វើសកម្មភាព ចំពោះការចាត់ចែងរក្សាការពារបានផងដែរ ដោយគ្រាន់តែធ្វើការចម្លងឯកសារជាផ្លូវការ រួចភ្ជាប់ជាមួយពាក្យសុំអនុវត្តតែម្តងជាការគ្រប់គ្រាន់។ នៅពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននៅសោហុយនៃការអនុវត្ត។ ប៉ុន្តែ បើអ្នកដែលដាក់ពាក្យសុំឱ្យអនុវត្តមិនបានបង់សោហុយសម្រាប់ការអនុវត្តជាមុននោះទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំនោះ ឬលុបចោលពាក្យសុំនោះតែម្តង។

## ៣ ការពិនិត្យមើលពាក្យសុំ

ពាក្យសុំឱ្យអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដូច្នេះពេលដែលតុលាការអនុវត្ត បានទទួលពាក្យសុំឱ្យអនុវត្តដីកាសម្រេច តុលាការត្រូវត្រួតពិនិត្យថាតើ ពាក្យសុំឱ្យធ្វើការអនុវត្តដីកាសម្រេចនោះ ស្របទៅនឹងលក្ខខណ្ឌនៃរបៀបដាក់ពាក្យសុំឱ្យធ្វើការអនុវត្តដីកាសម្រេចហើយ ឬ នៅ? ក្រៅពីនេះតុលាការអនុវត្តត្រូវពិនិត្យផងដែរ នូវឯកសារភ្ជាប់ដូចជាលិខិតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ បញ្ជីឈ្មោះរបស់ភាគីជាដើម។

## ៤ ការពិនិត្យលក្ខខណ្ឌចាំបាច់នៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

បន្ទាប់ពីពិនិត្យមើលរបៀបដាក់ពាក្យសុំ ឱ្យអនុវត្តដីកាសម្រេចនោះហើយ តុលាការអនុវត្តត្រូវពិនិត្យមើលលក្ខខណ្ឌចាំបាច់នានា នៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ព្រោះថាបើមិនបំពេញលក្ខខណ្ឌទាំងអស់នោះទេ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នមិនអាចអនុវត្តទៅបានឡើយ។

លក្ខខណ្ឌចាំបាច់ទាំងនោះមានដូចខាងក្រោម ៖

- លិខិយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ៖ តុលាការត្រូវពិនិត្យមើលថាតើ

[46] មាត្រា ៥៦២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ឈ្មោះរបស់ភាគីដែលមាននៅក្នុងពាក្យសុំអនុវត្តនោះ ដូចគ្នាទៅនឹងឈ្មោះរបស់ភាគីដែលមាននៅក្នុងដីកាសម្រេចដែរ ឬ ទេ? បើឈ្មោះដូចគ្នា គឺការអនុវត្តដីកាសម្រេចត្រូវធ្វើឡើងដោយផ្អែកទៅលើតែឯកសារចម្លងលិខិតយថាភូត នៃដីកាសម្រេចនោះតែប៉ុណ្ណោះ។ ប៉ុន្តែបើឈ្មោះរបស់ភាគីមិនដូចគ្នាទេ គឺការអនុវត្តត្រូវធ្វើឡើងដោយផ្អែកទៅលើឯកសារចម្លងយថាភូតលិខិតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត។

- អំឡុងពេល ៖ ការរឹបអូសជាបណ្តោះអាសន្នមិនត្រូវធ្វើឡើយ បើអំឡុងពេល២ សប្តាហ៍បានកន្លងហួសទៅ គិតចាប់ពីថ្ងៃដែលដីកាសម្រេចនោះត្រូវបានបញ្ជូនទៅដល់ម្ចាស់បំណុល[47]។ មូលហេតុនៃការកំណត់បែបនេះ គឺដើម្បីឱ្យម្ចាស់បំណុលធ្វើការអនុវត្តភ្លាមៗ ប្រសិនបើម្ចាស់បំណុលមិនបានធ្វើការអនុវត្តទេនោះនឹងមិនអានុភាពអនុវត្តទេ។ ក៏ប៉ុន្តែ វាជាគ្រប់គ្រាន់ណាស់ហើយក្នុងការចាប់ផ្តើមសកម្មភាពអនុវត្តក្នុងរយៈពេល ២ (ពីរ) សប្តាហ៍នេះ ចំណែកឯសកម្មភាពបន្តបន្ទាប់ទៀតមកនៃសកម្មភាពអនុវត្តមិនចាំបាច់ធ្វើក្នុងសកម្មភាពនោះទេ។ អំឡុងពេលនេះ មិនត្រូវបានកែប្រែជាថ្មី ដោយដីកាសម្រេចទទួលស្គាល់ការរឹបអូសជាបណ្តោះអាសន្ននេះ ដែលបានចេញដោយសារតែមានការដាក់ពាក្យតវ៉ានោះទេ។ ក៏ប៉ុន្តែ ក្នុងករណីដែលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានផ្អាកនៅមុនអំឡុងពេលនោះ ត្រូវចាត់ទុកថាអំឡុងពេលនោះមានដំណើរការតាំងពីដំបូង ចាប់តាំងពីពេលផ្អាក់នោះបានកន្លងផុតទៅ។

## ៥ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នមានមានច្រើនប្រភេទ ដោយគិតទៅតាមប្រភេទនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននោះមានដូចជា ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗទៀត និងការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ។

### ៥.១ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ

ចលនវត្ថុ គឺជាវត្ថុទាំងឡាយណាដែលក្រៅពីអចលវត្ថុ[48] ។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ត្រូវឡើងតាមរបៀបកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ[49]។

---

[47] មាត្រា ៥៦២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[48] មាត្រា ១២០ ក្រមរដ្ឋប្បវេណី ២០០៧

[49] មាត្រា ៥៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ប្រសិនបើចលនវត្ថុនោះជាប្រាក់វិញ អាជ្ញាសាលាមិនអាចដកហូតទុក ឬ ឱ្យកូនបំណុលនោះជាអ្នកថែរក្សាប្រាក់នោះបានឡើយ។ ដោយអាជ្ញាសាលាត្រូវតែផ្ញើប្រាក់ ដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននោះទៅតុលាការដែលខ្លួនស្ថិតនៅ។ ដូចដែលបានរៀបរាប់ហើយថា អាជ្ញាសាលាមិនអាចកាន់កាប់ប្រាក់នោះបានទេ តែអ្វីផ្សេងៗទៀតអាជ្ញាសាលាអាចកាន់កាប់បាន។ ក្នុងករណីដែលមានការបារម្ភថាចលនវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ននោះនឹងមានការធ្លាក់ថ្លៃជាពិសេសបើការទុកចលនវត្ថុនោះ នាំឱ្យមានការចំណាយសោហុយច្រើនពេក អាជ្ញាសាលាអាចលក់ចលនវត្ថុនោះបាន តាមវិធីនៃការលក់ដោយបង្ខំ។ នៅពេលដែលអាជ្ញាសាលាបានលក់ចលនវត្ថុនោះហើយ ប្រាក់ដែលបានមកពីការលក់នេះ អាជ្ញាសាលាមិនអាចធ្វើការកាន់កាប់បានទេ អាជ្ញាសាលាត្រូវយកប្រាក់ដែលបានមកពីការលក់នេះ ទៅផ្ញើនៅតុលាការដែលខ្លួនស្ថិតនៅ។

### ៥.២ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

អចលនវត្ថុសំដៅទៅលើ ដីធ្លី វត្ថុដែលនៅជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិជាដើម[50]។ ម៉្យាងវិញទៀត អចលនវត្ថុក៏សំដៅលើសិទ្ធិប្រត្យក្ស ឬសិទ្ធិ ភណ្ឌិតលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលច្បាប់បានកំណត់ថាជាអចលនវត្ថុ។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនធ្វើការអនុវត្តដូចចលនវត្ថុ ដោយធ្វើការកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលានោះទេ ។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលវត្ថុ កូនបំណុលអាចប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុនោះបានដោយធម្មតា។ ដូចនេះកូនបំណុល មិនចាំបាច់ចាកចេញពីអចលនវត្ថុនោះដោយសារការអនុវត្តនោះទេ។ លើសពីនេះទៅទៀត បើកូនបំណុលបានជួលអចលនវត្ថុនោះទៅឱ្យបុគ្គលដទៃទៀតមុនពេលធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ការជួលបន្តនៃអចលនវត្ថុនោះមិនប្រឆាំងនឹងអានុភាពនៃការរឹបអូសជាបណ្តោះអាសន្នឡើយ។ ប៉ុន្តែការជួលសារជាថ្មីនៃអចលវត្ថុទៅឱ្យអ្នកដទៃធ្វើក្រោយការអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺកូនបំណុលមិនអាចធ្វើទៅបានទេ បើទោះបីជាកូនបំណុលបានធ្វើកិច្ចសន្យាដែលបានធ្វើការព្រមព្រៀងធ្វើរវាងកូនបំណុល នឹងតតិយជនក៏ដោយ គឺនៅតែមិនអាចតតាំងជាមួយម្ចាស់បំណុលបានដែរ។ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈរបៀបដែលធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[51]។ ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះត្រូវបានចែកចេញជាពីរប្រភេទ គឺការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលធ្វើចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី និងការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែលធ្វើចំពោះ

[50] មាត្រា ១២០ ក្រមរដ្ឋប្បវេណី ២០០៧

[51] មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

អចលនវត្ថុដែលបានចុះបញ្ជី។ ការបែងចែកបែបនេះ ព្រោះថាការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលបានចុះបញ្ជី និងមិនទាន់បានចុះបញ្ជីមានលក្ខណៈខុសគ្នា ហើយការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលបានចុះបញ្ជីរួចមានលក្ខណៈងាយស្រួល ចំណែកឯការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈស្មុគស្មាញហើយពិបាកក្នុងការអនុវត្តណាស់។

**ក. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលបានចុះបញ្ជី** ៖ អចលនវត្ថុដែលបានចុះបញ្ជីរួច គឺសំដៅទៅលើអចលនវត្ថុណាដែលបានចុះបញ្ជីសុរិយោដីដើម្បីទទួលបានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ ( ប្លង់រឹង )។ ប្រសិនបើ អចលនវត្ថុដែលបានចុះបញ្ជីរួចហើយ គឺត្រូវធ្វើឡើងតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ ការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើដោយក្រឡាបញ្ជី។ ក្រឡាបញ្ជី ត្រូវធ្វើការផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[52]។ ស្ថាប័នដែលមានសមត្ថកិច្ច គឺសំដៅទៅដល់រដ្ឋបាលសុរិយោដី ថ្នាក់រាជធានី ខេត្ត រដ្ឋបាលសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ដែលអចលនវត្ថុនោះស្ថិតនៅ។ ការផ្ទុកផ្តាក់របស់ក្រឡាបញ្ជីនេះ ត្រូវធ្វើឡើងតាមរយៈលិខិតដែលមានឈ្មោះថា លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ហើយក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនលិខិតផ្ទុកផ្តាក់នោះទៅស្ថាប័នដែលមានសមត្ថកិច្ច។

**ខ. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី** ៖ អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសំដៅទៅលើដី ឬ ចំណែកឯកជនលើសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។ ម្យ៉ាងទៀតយើងអាចនិយាយថា អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី គឺជាអចលនវត្ថុទាំងឡាយណាដែលមិនទាន់មានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ ដោយមិនទាន់បានយកទៅចុះនៅក្នុងបញ្ជីសុរិយោដី (មិនទាន់មានប្លង់រឹង) ។ នៅក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នដូចគ្នា។ ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីទៅកាន់ស្ថាប័នដែលមានសមត្ថកិច្ច ឱ្យចាប់ផ្តើមក្នុងនីតិវិធីចុះបញ្ជីលើកដំបូង។ បន្ទាប់ពីទទួលលិខិតផ្ទុកផ្តាកឱ្យចុះបញ្ជីលើកដំបូងរួចហើយ រដ្ឋបាលសុរិយោដី គឺត្រូវចាប់ផ្តើមនីតិវិធីដោយគ្មានការយឺតយ៉ាវ ដោយត្រូវធ្វើការអនុវត្តតាមបទដ្ឋានគតិយុត្តដែលទាក់ទងទៅនឹងនីតិវិធីនៃការការចុះបញ្ជីលើកដំបូងជាធរមាន។

[52] មាត្រា ៥៦៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ៥.៣ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ សិទ្ធលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតត្រូវធ្វើឡើងតាមរបៀប ដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី៣ (បី) ធ្វើការសងទៅកូនបំណុល[53]។ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការអនុវត្តរក្សាការពារ គឺជាតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលអនុវត្តចំពោះសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតនេះមិនចាំបាច់សួរកូនបំណុល និងកូនបំណុលទី៣ (បី) ទេ។ ប៉ុន្តែ នៅក្នុងករណីដែលពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល ឬ ទ្រព្យសម្បត្តិផ្សេងទៀតត្រូវបានដកវិញ ឬ ត្រូវបានលុបចោលវិញក្រឡាបញ្ជីត្រូវតែធ្វើការជូនដំណឹងទៅកូនបំណុលទី៣(បី)[54]។ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិលើប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជី ហើយត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ដុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីថាសិទ្ធិលើបំណុលនោះ ត្រូវបានរឹបអូសហើយ[55]។ នៅក្នុងករណីដែលធ្វើការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណង ឱ្យសងជាប្រាក់ ប្រសិនបើកូនបំណុលទី៣ (បី) បានផ្ញើប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់ទាំងអស់ ឬ មួយផ្នែកនៃសិទ្ធិលើបំណុល នៅតុលាការ នោះនៅក្នុងចំនួនទឹកប្រាក់ទាំងអស់ដែលបានផ្ញើ ភាគដែលស្មើនឹងប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ននេះ ត្រូវចាត់ទុកថា ជាប្រាក់ដែលកូនបំណុលបានផ្ញើគឺជាប្រាក់រំដោះ ហើយភាគដែលលើសនេះ គឺត្រូវចាត់ទុកថាជាការសងចំពោះកូនបំណុលនៃការអនុវត្ត។

## ៥.៤ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

នាវា សំដៅទៅលើជលយានដែលមានចំណុះស្មើ ឬ លើសពី ២០ (ម្ភៃ) តោន ទោះបីជាមិនចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងជុលយានដែលមានចំណុះក្រោមពី ២០ (ម្ភៃ) តោនក៏ដោយឱ្យតែបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា[56] ។ លិខិតបញ្ជាក់សញ្ជាតិនាវា សំដៅទៅលើឯកសារដែលបញ្ជាក់សញ្ជាតិនាវា និងឯកសារផ្សេងទៀតដែលចាំបាច់ដើម្បីបើកបរនាវាដោយស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន។ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

[53] មាត្រា ៥៦៦ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[54] មាត្រា ៥០៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[55] មាត្រា ៥០៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[56] មាត្រា ៥៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ចំពោះនាវា គឺត្រូវធ្វើឡើងតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្ដល់លិខិតបញ្ជាក់សញ្ជាតិនាវានោះទៅឱ្យតុលាការរក្សាការពារ[57]។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលមិនមានទំនុកចិត្តលើការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ដោយការធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ឬ ធ្វើការរឹបអូសតាមវិធីដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ម្ចាស់បំណុលក៏អាចស្នើសុំទៅតុលាការឱ្យធ្វើការអនុវត្តរួមគ្នាតែម្ដងក៏បាន។តុលាការអាចធ្វើការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ដោយធ្វើតាមរបៀបចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នផង និងវិធីដកហូតយកសញ្ជាតិនាវាផងក៏បានដែរ។ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះនាវាដែលធ្វើតាមរបៀបនៃការចុះបញ្ជី អំពីការរឹបអូសជាបណ្ដោះអាសន្នតុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ។ ម្យ៉ាងវិញទៀតការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។ ការរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ដែលការរឹបអូសជាបណ្ដោះអាសន្នធ្វើឡើងតាមវិធីនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ញើផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននេះ។

[57] មាត្រា ៥៦៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# ជំពូកទី ៥ បណ្តឹងឧបាស្រ័យចំពោះការរឹបអូសជាបណ្តោះអាសន្ន

ភាគីដែលមិនសុខចិត្តទៅនឹងការសម្រេចសេចក្តីរបស់តុលាការ ភាគីអាចធ្វើការតវ៉ា ឬ ធ្វើបណ្តឹងជំទាស់បាននឹងសេចក្តីសម្រេចនោះបាន។ ហើយការតវ៉ាអាចធ្វើឡើងដោយ កូនបំណុល ឬ តតិយជនដែលមានការពាក់ពន្ធនឹងផលប្រយោជន៍។ តតិយជន អាចធ្វើការប្តឹងតវ៉ាលើការអនុវត្ត រឹបអូសជាបណ្តោះអាសន្នបាន ប្រសិនបើតតិយជននោះមានការពាក់ព័ន្ធនឹងផលប្រយោជន៍នោះ ដោយមានការអនុញ្ញាតពីច្បាប់។

## ១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ឱ្យកូនបំណុលណា ដែលមិនបានចូលរួមក្នុងនីតិវិធីជាមុនក្នុងសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃដីកាសម្រេចរក្សាការពារ ដោយដីកាសម្រេចរក្សាការពារនោះ មិនអាចប្តឹងជំទាស់ភ្លាមបានទេ។ បន្ទាប់ពីតុលាការបានចេញដីកាសម្រេចរក្សាការពាររួចហើយ កូនបំណុលដែលមិនសុខចិត្តនឹងដីកាសម្រេចនោះ អាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនោះ ទៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ[58]។

### ១.១ នីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ា

បន្ទាប់ពីតុលាការទទួលបានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការក៏ត្រូវគោរពនូវនីតិវិធីដែលច្បាប់បានបញ្ញត្តិទុក។

**ក. ការទាញហេតុផលដោយផ្ទាល់មាត់ ៖** នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចតវ៉ានេះ ក្រោយពីកូនបំណុលដាក់ពាក្យសុំលើដីកាសម្រេចរក្សាការពារនេះ តុលាការមិនអាចធ្វើការចេញដីកាសម្រេចតវ៉ានេះ ដោយមិនបានធ្វើការឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសាក់សួរភាគីបានទេ។ ដូចនេះ ក្រោយពីមានការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការកំណត់កាលបរិច្ឆេទឱ្យភាគីចូលរួមរួច ទើបតុលាការអាចចេញសេចក្តីសម្រេច។

**ខ. ការបញ្ចប់ការវិនិច្ឆ័យចំពោះការតវ៉ា ៖** ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យនោះ ដោយធ្វើការកំណត់ពេលវេលាដ៏សមរម្យបំផុតមួយ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបានតុលាការប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យ។

[58] មាត្រា ៥៥០ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

**គ. ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរក្សាការពារ ៖** នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារតុលាការត្រូវទទួលស្គាល់ ឬ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ[59]។ ប្រសិនបើតុលាការបានចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល តុលាការអាចដាក់លក្ខខណ្ឌតម្រូវឱ្យកូនបំណុលដាក់ប្រាតិភោគបាន។ ក្រោយពេលដែលតុលាការបានចេញដីកាសម្រេច អំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារនេះ ដោយបានទទួលស្គាល់ ឬ ផ្លាស់ប្តូរ ឬ លុបចោលដីកាសម្រេចរក្សាការពាររួចមក តុលាការត្រូវធ្វើការបញ្ជូនដីកាសម្រេចនេះទៅឱ្យភាគី។

## ២ ការតវ៉ាចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការតវ៉ាចំពោះការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននេះ គឺជាបណ្តឹងដែលធ្វើការតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត។

**ក. បណ្តឹងតវ៉ារបស់តតិយជន ៖** មិនមែនមានតែគូភាគីទេដែលមានសិទ្ធិក្នុងការតវ៉ាចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្នទេ ប៉ុន្តែតតិយជនក៏អាចធ្វើការតវ៉ាចំពោះការរឹបអូសជាបណ្តោះអាសន្នបានផងដែរ នៅក្នុងករណីដែលតតិយជនមានការពាក់ព័ន្ធ និងមានការប៉ះពាល់ផលប្រយោជន៍។ ផលប្រយោជន៍ដែលតតិយជនមាន កម្មសិទ្ធិ ឬ សិទ្ធិផ្សេងៗទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ននោះ។ តតិយជនក៏អាចធ្វើការតវ៉ាមិនត្រឹមតែចំពោះអចលនវត្ថុទេ គឺថែមទាំងចលនវត្ថុទៀតផង ដែលអាចដាក់ទៅស្ថាប័នអនុវត្តដែលជាតុលាការអនុវត្ត ឬ អាជ្ញាសាលាមិនថាមានគោលបំណងឱ្យសងជាប្រាក់ ឬ គ្មានគោលបំណងសងជាប្រាក់នោះទេ។

**ខ.សមត្ថកិច្ច ៖** ការតវ៉ា គឺជាវិធីឧបាស្រ័យមួយប្រភេទ ទៅតុលាការថ្នាក់ដដែល ដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ។ ការតវ៉ានេះអាចធ្វើឡើងនៅពេលណាក៏បានដែរ ឱ្យតែមានការទាក់ទងផលប្រយោជន៍ ហើយមិនកំណត់អំឡុងពេលសម្រាប់ធ្វើការតវ៉ា ដូចទៅនឹងបណ្តឹងជំទាស់នោះទេ។ ប៉ុន្តែ នៅក្នុងករណីដែលមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលបានចេញដោយសាលាឧទ្ធរណ៍ ក្នុងនាមជាតុលាការអនុវត្តវិញ គឺត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ។

[59] មាត្រា ៥៥៩ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## ៣ ការសុំឱ្យលុបចោល និងការផ្អាកលើដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ មិនត្រឹមតែត្រូវបានលុបចោលដោយតវ៉ានោះទេ គឺត្រូវបានលុបចោលដោយករណីដូចជា៖

-ការលុបចោលដោយសាការមិនដាក់បណ្ដឹងអង្គសេចក្ដី តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះ ក្នុងអំឡុងពេលសមរម្យតាមពាក្យសុំរបស់កូនបំណុល[60]។

-ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព ប្រសិនបើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរស្ថានភាពផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី អាចលុបដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុលបាន[61]។

-ការលុបចោលដោយស្ថានភាពពិសេស ប្រសិនបើមានការបារម្ភថាមានការខូចខាតដែលមិនអាចសងបាននឹងកើតមានឡើងដោយសារការអនុវត្តរក្សាការពារ គឺតុលាការអាចលុបចោលដីការក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន[62]។

ក្នុងករណីដែលមានពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្តតាមពាក្យសុំបាន ដោយតម្រូវឱ្យដាក់ប្រាតិភោគរហូតដល់ធ្វើការសម្រេចសេចក្ដី អំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារថាតើទទួលស្គាល ឬ លុបចោល ឬ ផ្លាស់ប្ដូរនូវសេចក្ដីសម្រេចនោះសិន[63]។

## ៤ បណ្ដឹងជំទាស់

បណ្ដឹងជំទាស់ គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ ហើយយើងអាចនិយាយម្យ៉ាងទៀតបានថា បណ្ដឹងជំទាស់ គឺជាបណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចកនានាដែលតុលាការបានចេញក្នុងរឿងក្ដីដែលមានការទាក់ទងទៅនឹងការរក្សាការពារនៅក្នុងករណីមួយចំនួនដែលច្បាប់បានចែងទុកជាមុន។

បណ្ដឹងជំទាស់អាចធ្វើបានអាស្រ័យដោយមូលហេតុដូចខាងក្រោម ៖

- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។

[60] មាត្រា ៥៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[61] មាត្រា ៥៥៨ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[62] មាត្រា ៥៥៩ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[63] មាត្រា ៥៥១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

- ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន។
- ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ។
- ដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ។

## ៥ នីតិវិធី និងអំឡុងពេលបណ្តឹងជំទាស់

បណ្តឹងជំទាស់នៃរឿងក្តីរក្សាការពារត្រូវបានកំណត់ត្រឹមរយៈពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបញ្ជូនដីកាសម្រេចនោះទៅដល់អ្នកដែលមានសិទ្ធិធ្វើបណ្តឹងជំទាស់។ រយៈពេលដែលកំណត់ខាងលើនេះមិនពន្យាពេលបានឡើយ[64]។

នីតិវិធីនៃបណ្តឹងជំទាស់ ជានីតិវិធីមួយដែលមានរយៈពេលយូរ ឬ យឺតជាងការតវ៉ា។ បណ្តឹងជំទាស់ក៏អនុវត្តដូចនីតិវិធីនៃការតវ៉ាខ្លះដែរ។

**ការទាញហេតុផលដោយផ្ទាល់មាត់ ៖** នៅក្នុងបណ្តឹងជំទាស់ចំពោះ នីតិវិធីចាត់ចែងរក្សាការពារ តុលាការចាំបាច់ត្រូវតែធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយត្រូវធ្វើការកំណត់ពេលដ៏សមរម្យ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលអាចឱ្យភាគីដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍អាចចូលរួមបាន។

**ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់ ៖** ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់មានលក្ខណៈដូចគ្នាទៅនឹងការបញ្ចប់ការវិនិច្ឆ័យការតវ៉ាដែរ ដោយតុលាការត្រូវធ្វើការកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យដើម្បីធ្វើការបញ្ចប់ការវិនិច្ឆ័យ។ ប៉ុន្តែ បើតុលាការបានកំណត់កាលបរិច្ឆេទហើយ តុលាការអាចប្រកាសភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ដូចដែលបានកំណត់ទៅតាមកាលបរិច្ឆេទ[65]។

## ៦ ការសុំឱ្យជំនុំជម្រះសារជាថ្មី

ប្រសិនបើនៅពេលដែលផុតអំឡុងពេលនៃបណ្តឹងជំទាស់ គូភាគីដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍នៃរឿងក្តីចាត់ចែងរក្សាការពារ អាចធ្វើការដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាននៅពេលដែលដីកាសម្រេចនោះបានចូលជាស្ថាពរ[66]។

[64] មាត្រា ៥៦១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[65] មាត្រា ៥៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[66] មាត្រា ៥៦១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវលើប្រធានបទ " នីតិវិធីនៃការចាត់ចែងរក្សាការពារចំពោះការរឹបអូសជាបណ្ដោះអាសន្ន " រួចមក ខ្ញុំបាទអាចសន្និដ្ឋានបានថា នីតិវិធីនៃការចាត់ចែងរក្សាការពារចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន គឺជានីតិវិធីមួយដែលមានលក្ខណៈបណ្ដោះអាសន្ន ដើម្បីការពារផលប្រយោជន៍ម្ចាស់បំណុល នៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបាន ឬ ការសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលមិនអាចប្រព្រឹត្តទៅបានដោយសារតែការផ្លាស់ប្ដូរស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬ អាចនិយាយម្យ៉ាងទៀតបានថា ដើម្បីរក្សាឱ្យបានស្ថិតស្ថេរ មិនឱ្យកូនបំណុលធ្វើការផ្ទេរកម្មសិទ្ធិបាន ដើម្បីធានាដល់សិទ្ធិលើការទាមទាររបស់ម្ចាស់បំណុលនៅក្នុងករណីដែលមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដោយសារតែមានវិវាទទាក់ទងទៅនឹងសិទ្ធិ ទើបមានការរឹបអូសជាបណ្ដោះអាសន្នលើវត្ថុដែលមានវិវាទ ដើម្បីទទួលបានសំណងក្នុងករណីដែលកូនបំណុលគេចវេសមិនទទួលខុសត្រូវ។ ការរឹបអូសជាបណ្ដោះអាសន្ន បើយើងសង្កេតមើលទៅលើវាហាក់ដូចជាការពារសិទ្ធិរបស់ម្ចាស់បំណុលខ្លាំងណាស់ ក៏ប៉ុន្តែគឺដើម្បីការពារពីចេតនាទុច្ចរិតរបស់កូនបំណុលក្នុងការចាត់ចែងទ្រព្យសម្បត្តិដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ ហើយយើងក៏អាចនិយាយបានដែរថា វាដូចជាសមហេតុផល និងត្រឹមត្រូវដែរ ការរឹបអូសជាបណ្ដោះអាសន្ន គឺគ្រាន់តែកម្រិតនៅសិទ្ធិចាត់ចែងរបស់កូនបំណុលតែប៉ុណ្ណោះ ហើយគេមិនបានបិទសិទ្ធិរបស់កូនបំណុលក្នុងការតវ៉ាសេចក្ដីសម្រេចរបស់តុលាការនោះទេ ពោលគឺកូនបំណុលអាចប្ដឹងតវ៉ាចំពោះដីការក្សាការពារដែលធ្វើចំពោះការរឹបអូសជាបណ្ដោះអាសន្នបាន ប្រសិនបើខ្លួនយល់ឃើញថាការសម្រេចសេចក្ដីនោះធ្វើឡើងដោយមានភាពអយុត្តិធម៌ ។ ការរឹបអូសជាបណ្ដោះអាសន្ន អាចមានការប៉ះពាល់ផលប្រយោជន៍យ៉ាងខ្លាំងទៅភាគីណាម្ខាង ប្រសិនបើតុលាការមិនបានដើរតួនាទី អព្យាក្រឹត្យ និង ឯករាជ្យ ដែលខ្លួនជាអ្នកសម្រេចសេចក្ដី។ ការរឹបអូសជាបណ្ដោះអាសន្ន កម្រិតនូវសិទ្ធិសេរីភាពរបស់កូនបំណុលនៅក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ប្រសិនបើតុលាការបានធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្ដីចំពោះពាក្យសុំរបស់ម្ចាស់បំណុលដោយផ្អែកទៅលើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត និងភាពចាំបាច់នានាដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចនោះ បើពិនិត្យមើលលក្ខខណ្ឌមានគ្រប់ហើយនោះ តុលាការចេញដីកាសម្រេចនោះមានន័យថា ការសម្រេចសេចក្ដីនោះត្រឹមត្រូវ ព្រោះដើម្បីការពារការលួចចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដោយចេតនាទុច្ចរិត ក្នុងការគេចវេសពីការទទួលខុសត្រូវនៅក្នុងការអនុវត្តកាតព្វកិច្ចចំពោះម្ចាស់បំណុល។

សរុបសេចក្ដីមក នីតិវិធីនៃការចាត់ចែងរក្សាការពារចំពោះការរឹបអូសជាបណ្ដោះអាសន្ន គឺវាមានលក្ខណៈបណ្ដោះអាសន្ន និងឆាប់រហ័សដោយមិនចាំបាច់រង់ចាំ រហូតដល់សាលក្រម ឬ សាលដីកាចូលជាស្ថាពរ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីដែលអាចទទួលការខាតបង់ដែលនឹងអាចកើតមានឡើងជាពុំខាន បើមិនប្រញាប់ចាត់ចែងឱ្យទាន់ពេលវេលានោះទេ ។ ប្រសិនបើកូនបំណុលមិនពេញចិត្តនឹងសេចក្ដីសម្រេចដែលទាក់ទងទៅនឹងការអវត្តរឹបអូសជាបណ្ដោះអាសន្ន កូនបំណុលអាចធ្វើការតវ៉ា ឬ ប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចនោះបាន។

# អនុសាសន៍

នីតិវិធីនៃការចាត់ចែងរក្សាការពារចំពោះការរឹបអូសជាបណ្តោះអាសន្ននេះ គឺមានការលំបាកខ្លាំងណាស់ក្នុងការសម្រេចសេចក្តី ព្រោះក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសកម្ពុជាយើងត្រូវបានស្ថាបនានិងឧបត្ថមដោយប្រទេសជប៉ុនដោយធ្វើការអនុវត្តតាមរបៀបប្រទេសជប៉ុន ដូចនេះតម្រូវឱ្យអ្នកច្បាប់គ្រប់មជ្ឈដ្ឋាន គួរតែស្វែងយល់ឱ្យបានស៊ីជម្រៅជាពិសេសអ្នកអនុវត្តច្បាប់ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីលើកស្ទួយវិស័យយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាយើង។

ម្ចាស់បំណុលគប្បីតែប្រញាប់ញាលក្នុងការដាក់ពាក្យសុំរក្សាការពារ ក្នុងករណីដែលខ្លួនបានដឹងពីចេតនាទុច្ចរិតរបស់កូនបំណុល ឬ ក្នុងករណីដែលខ្លួនមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងដើម្បីបង្កាទុកពីហានិភ័យដែលកើតឡើងដោយថាហេតុដោយចេតនាទុច្ចរិតរបស់កូនបំណុលក្នុងការគេចវេសពីការទទួលខុសត្រូវចំពោះម្ចាស់បំណុល។

តុលាការគប្បីត្រូវយកចិត្តទុកដាក់ នៅក្នុងការបញ្ជូនដីកាសម្រេចរក្សាការពារនេះទៅឱ្យភាគីដើម្បីឱ្យអ្នកដែលត្រូវទទួលការបញ្ជូនដីកាសម្រេចនោះអាចរកមធ្យោបាយការពារខ្លួន និងដាក់ភស្តុតាងដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនបានទាន់ពេលវេលា។

ចៅក្រមដែលជាអ្នកសម្រេចសេចក្តី ត្រូវតែធ្វើការសម្រេចសេចក្តីត្រូវពិនិត្យមើលលក្ខខណ្ឌចាំបាច់នានាដើម្បីសម្រាប់ការចេញដីកាសម្រេច និងពិចារណា មុនធ្វើការសម្រេចសេចក្តី។ ចៅក្រមត្រូវយកចំណេះដឹង និងសមត្ថភាពដែលខ្លួនមានយកមកប្រើឱ្យអស់លទ្ធភាព។ ចៅក្រមមិនត្រូវសម្រេចសេចក្តីដោយអគតិទាំងបួន គឺ **ភ័យោគតិ ឆន្ទាគតិ មោហាគតិ** និង **ទោសាគតិ។**

# ឯកសារយោង

- ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។
- ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៧។
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគ២ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ ឆ្នាំ ២០០៩។
- ឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី០៤ នីតិវិធីរក្សាការពារ របស់សាស្ត្រាចារ្យ កេត សុជាតិ ឆ្នាំ ២០១៦។
- ឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី០៤ នីតិវិធីបញ្ជូន របស់សាស្ត្រាចារ្យ ហេង សុខណា ឆ្នាំ ២០១៦។